# **សេចក្តីថ្លែងការណ៍រួម**

## **ស្តីពីការហាមឃាត់សិទ្ធិសេរីភាពក្នុងការដើរហើរ**

ᯤᯤᯤ ❋ ᯤᯤᯤ

ក្រុមអង្គការសង្គមស៊ីវិល ថ្កោលទោសចំពោះតំណាងក្រុមហ៊ុន Socfin-KCD ដែលបានឃាត់ក្រុមអង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋមួយចំនួន ក្នុងដំណើរទស្សនកិច្ចសិក្សា ស្វែងយល់អំពីវប្បធម៌ ប្រពៃណីរបស់ជនជាតិដើមភាគតិច ព្រៃភ្នំ ទឹកជ្រោះ តំបន់ជំរកសត្វព្រៃ នៅក្នុងឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ដោយអះអាងថាដីតំបន់នោះគឺជាទ្រព្យសម្បត្តិឯកជនរបស់ក្រុមហ៊ុនផ្តាច់មុខ។

កាលពីថ្ងៃទី ២១ ខែមករា ឆ្នាំ២០១០ ក្រុមអង្គការសង្គមស៊ីវិល និងសហគមន៍មកពីបណ្តាខេត្តផ្សេងៗ ចំនួនប្រហែលជាសាមសិបនាក់ បានធ្វើដំណើរទៅទស្សនកិច្ចសិក្សាអំពីព្រៃធម្មជាតិនៅក្នុងតំបន់អភិរក្សភ្នំណាមល្យើរ ស្ថិតនៅឃុំប៊ូស្រា ស្រាប់តែមានរថយន្តរបស់ក្រុមហ៊ុន Socfin-KCD ដែលមានតំណាងឈ្មោះលោក ព្យែ (Pierre) បានដេញតាមពីក្រោយ និងឃាត់ដំណើរ ដោយសំដែងអាកប្បកិរិយាមិនសមរម្យ គំរាមកំហែង ព្រមទាំងគំរាមមិនអោយថតរូបភាពព្រៃធម្មជាតិផ្សេងៗ ដោយចាត់ទុកតំបន់នោះជាទ្រព្យសម្បត្តិឯកជនរបស់ក្រុមហ៊ុន និងមិនឱ្យអ្នកណាចេញ-ចូលបានឡើយ។

ក្រុមហ៊ុន Socfin-KCD គឺជាក្រុមហ៊ុនដែលមានភាគហ៊ុនរបស់ក្រុមហ៊ុនបារាំង ដែលទទួលបានសម្បទានដីសេដ្ឋកិច្ចពីរាជរដ្ឋាភិបាលកម្ពុជា កាលពីឆ្នាំ២០០៨ នូវទំហំដីចំនួន ២៧០៥ ហិចតា ដើម្បីអភិវឌ្ឍន៍ដាំដំណាំកៅស៊ូនៅក្នុងឃុំប៊ូស្រា ខេត្តមណ្ឌលគិរី។ ចាប់តាំងពីក្រុមហ៊ុននេះបោះទីតាំងនៅតំបន់នោះមក ក្រុមហ៊ុននេះបានដាក់របាំងបិទផ្លូវមិនឱ្យប្រជាពលរដ្ឋធ្វើដំណើរឆ្លងកាត់ ឬចេញ-ចូល ដែលផ្លូវនេះពីមុនគឺជាផ្លូវសាធារណៈរបស់រដ្ឋ ហើយអាចទៅដល់តំបន់រម្យណីដ្ឋានផ្សេងៗ ដូចជា ទឹកជ្រោះ ភ្នំប្រវត្តិសាស្ត្រ និងតំបន់ព្រៃអភិរក្ស និងអាចទៅដល់ច្រកព្រំដែនកម្ពុជា-វៀតណាមផងដែរ។ ប្រជាពលរដ្ឋជនជាតិដើមភាគតិច ដែលរស់នៅតំបន់នោះក៏ត្រូវបានរឹតបន្តឹងក្នុងការអនុញ្ញាតឱ្យចូលដើម្បីប្រកបរបរចិញ្ចឹមជីវិត និងចូលទៅតំបន់ជំនឿ និងគោរពបូជា តាមបែបប្រពៃណីយ៍ សាសនារបស់ខ្លួនផងដែរ។

យោងតាមរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា៤០ ចែងថា "សេរីភាពក្នុងការដើរឆ្ងាយជិត... ត្រូវបានគោរព" និងមាត្រា ៥៨ បានចែងថា "ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាទសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក បឹង ព្រៃឈើ...បានកំណត់ថាជារបស់រដ្ឋ" ។

អង្គការសង្គមស៊ីវិលចាត់ទុកទង្វើរបស់បុគ្គលរូបនេះ គឺជាការគំរាមកំហែង បំបាក់ស្មារតី និងបានរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ជាពិសេសសិទ្ធិសេរីភាពក្នុងការដើរហើរ ដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ។

អង្គការសង្គមស៊ីវិលយល់ថា រាជរដ្ឋាភិបាលបានផ្តល់សម្បទានដីសេដ្ឋកិច្ចទៅឱ្យក្រុមហ៊ុន Socfin-KCD តែមិនមានន័យថា ផ្លូវធ្វើដំណើរ ព្រៃ ភ្នំ ទឹកជ្រោះ និងរម្យណីយដ្ឋានទេសចរណ៍នានា នៅឃុំប៊ូស្រា ត្រូវបានប្រគល់ឱ្យទៅក្រុមហ៊ុន Socfin-KCD ទាំងអស់នោះទេ។

ក្រុមអង្គការសង្គមស៊ីវិល សូមធ្វើការអំពាវនាវដល់ក្រុមហ៊ុន Socfin-KCD ឱ្យបញ្ឈប់តំណាងរូបនេះ ចេញពីក្រុមហ៊ុន និងសូមអំពាវនាវផងដែរដល់អាជ្ញាធរខេត្តមណ្ឌលគិរី និងរាជរដ្ឋាភិបាល មេត្តាជួយធ្វើអន្តរាគមន៍ និងចាត់វិធានការចំពោះបុគ្គលរូបនេះទៅតាមច្បាប់ ព្រមទាំងបើកផ្លូវឱ្យប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការធ្វើដំណើរចេញ-ចូល ដើម្បីប្រកបរបរចិញ្ចឹមជីវិត និងភ្ញៀវទេសចរណ៍អាចចូលទៅទស្សនាតំបន់រម្យណីយដ្ឋានធម្មជាតិទាំងនោះដោយគ្មានការរារាំង ដើម្បីជាការលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា ។

មណ្ឌលគិរី, ថ្ងៃទី២២ ខែមករា ឆ្នាំ២០១០

**ពត៌មានបន្ថែមសូមទាក់ទង:**

-លោក **ឯម សុភក្រ្ត** មន្ត្រីគំរោង CLEC ទូរស័ព្ទលេខ: ០១២ ៩៧៨ ៩៣៥

-លោក **គល់ មីឌី** អ្នកសំរបសំរួលសមាគមអាដហុក ទូរស័ព្ទលេខ: ០១១ ៦២៣ ១០៥

-លោក **សួន សារ៉េត** ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការប្រព្រឹត្តិកម្ម ទូរស័ព្ទលេខ: ០៩២ ៣៨៤ ៣៩៧

**អង្គការ-សមាគម ដែលគាំទ្រលើសេចក្តីថ្លែងការណ៍នេះរួមមាន:**

-សមាគមការពារសិទ្ធិមនុស្ស ADHOC

-មជ្ឈមណ្ឌអប់រំច្បាប់សំរាប់សហគមន៍ CLEC

-វេទិការអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា NGO Forum

-លេខាធិការដ្ឋាន គណៈកម្មាធិការប្រព្រឹត្តិកម្ម CHRAC Secretariat

-អង្គការរក្សាការពារសិទ្ធិមនុស្សនៅកម្ពុជា VIGILANCE

-អភិវឌ្ឍន៍សំលេងសហគមន៍ BCV

-អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច ICSO

-អភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព DPA

-អង្គការភូមិខ្ញុំ MVI

-អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា LAC

-អង្គការសរសរទ្រូង SST

-បណ្តាញអង្គការមិនមែនរដ្ឋាភិបាលខេត្តមណ្ឌលគិរី MNN

-អង្គការ Caritas ។